**សម្ព័ន្ធអង្គការសង្គមស៊ីវិលប្រឆាំងអំពើពុករលួយ**

Coalition of Civil Society Organizations Against Corruption

## សេចក្តីថ្លែងការណ៍របស់សម្ព័ន្ធអង្គការសង្គមស៊ីវិលកម្ពុជាប្រឆាំងអំពើពុករលួយ
## ក្នុងឱកាស
## សន្និសីទកាសែតស្តីពី យុទ្ធនាការប្រមូលស្នាមមេដៃ និងហត្ថលេខា ១លាន ប្រឆាំងនឹងអំពើពុករលួយ
## ថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០០៨
## សណ្ឋាគារភ្នំពេញ

មកដល់ពេលនេះ យុទ្ធនាការរយៈពេល៥ខែ របស់អង្គការសង្គមស៊ីវិលកម្ពុជាប្រឆាំងនឹងអំពើពុករលួយដើម្បីប្រមូលស្នាមមេដៃ ឬហត្ថលេខាពីប្រជាពលរដ្ឋខ្មែរដែលមានអាយុគ្រប់បោះឆ្នោត ចំនួន១លាននាក់ដើម្បីបញ្ជាក់ពីឆន្ទៈនិងការទាមទារឱ្យមានការអនុម័ត ច្បាប់ប្រឆាំងអំពើពុករលួយបានបញ្ចប់ជាគោលការណ៍រួចហើយ ពោលគឺតាំងពីដំណាច់ខែមេសាកន្លងមក។ ក៏ប៉ុន្តែញត្តិនេះនៅតែបើកចំហជានិច្ចសម្រាប់ការបន្តចូលរួមគាំទ្រពីសំណាក់ប្រជាពលរដ្ឋទូទៅដែលមានវ័យអាចបោះឆ្នោតបាន ហើយចំនួនអ្នកដែលបានផ្តិតមេដៃ ឬចុះហត្ថលេខាគាំទ្រញត្តិនេះចេះតែបន្តកើនឡើងជាលំដាប់ ថ្វីបើវាពុំមានចំនួនច្រើន និងកើនឡើងលឿនដូចកាលដែលយើងចុះធ្វើយុទ្ធនាប្រមូលដល់ទីកន្លែង ពោលគឺអាស្រ័យទៅតាមលទ្ធភាពនិងឆន្ទៈផ្ទាល់របស់ប្រជាពលរដ្ឋ។

ទោះជាយ៉ាងណាក៏ដោយ នេះជាសក្ខីភាពមួយយ៉ាងជាក់ច្បាស់ថា ប្រជាពលរដ្ឋខ្មែរចំនួនច្រើនលើសលប់មានការព្រួយបារម្ភអំពីស្ថានភាពនៃអំពើពុករលួយនៅក្នុងសង្គមជាតិដែលកាន់តែមានសភាពធ្ងន់ធ្ងរទៅៗជាលំដាប់ ដែលបាន និងកំពុងកើតមាន ឡើងនៅស្ទើរគ្រប់ទិសទី និងស្ទើរគ្រប់ពេលវេលា ហើយគ្មានសញ្ញាណាមួយនាំឱ្យយើងជឿថាវានឹងថយចុះទៅវិញនោះឡើយដរាបណានៅតែគ្មានចំណាត់ការឱ្យបានម៉ឺងម៉ាត់ទេនោះ។

ការខកខានអស់រយៈពេលជាង១ទសវត្ស ក្នុងការមិនបានធ្វើច្បាប់មួយស្របតាមបទដ្ឋានអន្តរជាតិសម្រាប់ប្រយុទ្ធប្រឆាំងអំពើពុករលួយកាន់តែធ្វើឱ្យប្រជាពលរដ្ឋ និងសង្គមស៊ីវិលមានការព្រួយបារម្ភថែមទៀត ជាពិសេសចំពោះប្រសិទ្ធភាព និង ល្បឿននៃការកាត់បន្ថយភាពក្រីក្រ ដោយហេតុថាបើទោះបីជាមានកំណើនសេដ្ឋកិច្ចបែបណាក៏ដោយ អំពើពុករលួយនឹងធ្វើឱ្យផលនៃកំណើននោះប្រមូលផ្តុំទៅលើមនុស្សតែមួយក្រុមតូចប៉ុណ្ណោះ ឯប្រជាពលរដ្ឋក្រីក្រទន់ខ្សោយភាគច្រើនលើសលប់មិនបានទទួលផលសមគួរពីកំណើននោះឡើយ។ នេះមិននិយាយដល់ផលប៉ះពាល់ផ្នែកសេដ្ឋកិច្ចសង្គម និងភាពអយុត្តធម៌សង្គមផ្សេងៗទៀតផងទេ។ សង្គមស៊ីវិលបាន និងកំពុងបំពេញតួនាទីរបស់ខ្លួនយ៉ាងសកម្ម ដោយចុះទៅធ្វើការអប់រំដល់ប្រជាពលរដ្ឋ ឱ្យបានយល់ដឹងអំពីអំពើពុករលួយ និង ផលប៉ះពាល់នៃអំពើពុករលួយទៅលើជីវភាពប្រចាំថ្ងៃរបស់ពួកគេ និងទៅលើអនាគតកូនចៅរបស់ពួកគេ ហើយបានទទួលការគាំទ្រ និងការចូលរួមយ៉ាងសកម្មពីប្រជាពលរដ្ឋទាំងនោះមកវិញ តួយ៉ាងដូចជាការចុះហត្ថលេខាឬផ្តិតមេដៃគាំទ្រញត្តិប្រឆាំងអំពើពុករលួយ នេះជាសក្ខីភាពស្រាប់។ តែទោះជាយ៉ាងណាក៏ដោយ ការអប់រំតែម្យ៉ាង មិនអាចមានប្រសិទ្ធភាពគ្រប់គ្រាន់នឹងប្រយុទ្ធប្រឆាំងអំពើពុករលួយបានឡើយ។ ដើម្បីប្រយុទ្ធប្រឆាំង អំពើពុករលួយដោយប្រសិទ្ធភាព ត្រូវតែមាន

ចំណាត់ការមួយដែលមានលក្ខណៈជាប្រព័ន្ធ ពោលគឺត្រូវមានច្បាប់ដ៏រឹងមាំមួយដើម្បីបង្ការផង និងសម្រាប់ដាក់ទោសមនុស្សឱ្យខ្លាច និងរាងចាលផង។

អាស្រ័យហេតុនេះហើយ ទើបសម្ព័ន្ធអង្គការសង្គមស៊ីវិលកម្ពុជាប្រឆាំងអំពើពុករលួយ ដែលមានចំនួន៤៩ អង្គការជាតិ អន្តរជាតិ និងមូលដ្ឋាន បានផ្តួចផ្តើមធ្វើយុទ្ធនាការប្រមូលហត្ថលេខាចំនួន១លាននេះឡើង ក្នុងគោលបំណងធំៗពីរគឺៈ ជួយដល់រាជរដ្ឋាភិបាលក្នុងការអប់រំមហាជននិងប្រមូលស្នាមមេដៃឬហត្ថលេខាពីប្រជាពលរដ្ឋមកវិញ ដើម្បីជាតឹកតាងបង្ហាញជូនរដ្ឋសភា និង រាជរដ្ឋាភិបាលអំពីឆន្ទៈ ក្តីកង្វល់ និងបំណងប្រាថ្នាពិតប្រាកដរបស់ប្រជាពលរដ្ឋដែលជាម្ចាស់ឆ្នោត និងជាម្ចាស់អំណាច ពោលគឺចង់ឃើញចំណាត់ការម៉ឺងម៉ាត់របស់រាជរដ្ឋាភិបាល និងរដ្ឋសភា ក្នុងការប្រយុទ្ធប្រឆាំងអំពើពុករលួយ ជាពិសេសគឺអនុម័តច្បាប់ប្រឆាំងអំពើពុករលួយមួយដែលមានកម្រិតបទដ្ឋានអន្តរជាតិ ឱ្យបានយ៉ាងយូរបំផុតនៅក្នុងរយៈពេលប៉ុន្មានខែដំបូងនៃអាណត្តិថ្មីរបស់រាជរដ្ឋាភិបាល។

ជាមួយគ្នានេះដែរ សង្គមស៊ីវិលពិនិត្យឃើញថា គុណភាពនៃសេចក្តីព្រាងច្បាប់ប្រឆាំងអំពើពុករលួយបច្ចុប្បន្ន នៅមិនទាន់បានដល់កម្រិតបទដ្ឋានអន្តរជាតិ ដូចដែលរាជរដ្ឋាភិបាលបានយល់ព្រមជាមួយនឹងសហគមន៍ម្ចាស់ជំនួយនៅក្នុងកិច្ចប្រជុំពិគ្រោះយោបល់កាលពីខែធ្នូ ឆ្នាំ២០០៤ នោះនៅឡើយ។ អាស្រ័យហេតុនេះ សម្ព័ន្ធអង្គការសង្គមស៊ីវិល ក៏ទាមទារផងដែរឱ្យរាជរដ្ឋាភិបាល និងរដ្ឋសភា ពិនិត្យមើល និងកែសម្រួលឡើងវិញនូវចំណុចទាំងប៉ុន្មានខាងក្រោមក្នុងសេចក្តីព្រាង មុននឹងឈានទៅអនុម័តៈ

**១. ការកំណត់និយមន័យនៃអំពើពុករលួយ**

**២. ឯករាជភាពនៃស្ថាប័នប្រឆាំងអំពើពុករលួយ**

**៣. ការប្រកាសទ្រព្យសម្បត្តិ**

**៤. ការការពារអ្នករាយការណ៍ និងសាក្សី**

សូមបញ្ជាក់ថាខ្លឹមសារលំអិតនៃចំណុចទាំង៤ខាងលើនេះ សង្គមស៊ីវិលបានដាក់ជូនរាជរដ្ឋាភិបាល និងរដ្ឋសភា ពិចារណាជាច្រើនលើកច្រើនសាររួចមកហើយ ក៏ប៉ុន្តែមកដល់ពេលនេះ ពុំមានពតិមានអ្វីដែលបញ្ជាក់ថាសេចក្តីព្រាងច្បាប់បច្ចុប្បន្នត្រូវបានកែលំអដោយយកមតិយោបល់សង្គមស៊ីវិលខាងលើ ទៅធ្វើការពិចារណានោះឡើយ។ ថ្វីបើរដ្ឋសភាបានទទួលយកញត្តិនេះរួចហើយកាលពីថ្ងៃទី១៦ ខែឧសភា កន្លងមក ក៏ប៉ុន្តែរដ្ឋសភានៅតែមិនបានធ្វើការសន្យា ឬធានាអ្វីជាក់លាក់ចំពោះពលរដ្ឋម្ចាស់ឆ្នោតថានឹងជួយជម្រុញរាជរដ្ឋាភិបាលឱ្យបញ្ជូនសេចក្តីព្រាងច្បាប់មករដ្ឋសភា ដើម្បីពិនិត្យនិងអនុម័តឱ្យបានឆាប់នោះឡើយ ដោយគ្រាន់តែអះអាងថា នៅពេលណារាជរដ្ឋាភិបាលផ្ញើពង្រាងច្បាប់មកដល់រដ្ឋសភា នៅពេលនោះរដ្ឋសភានឹងយកពង្រាងច្បាប់មកពិនិត្យមើលឱ្យបានឆាប់រហ័ស។ ដោយឡែក តាំងពីពាក់កណ្តាលខែមេសាកន្លងមក រហូតមកដល់ពេលនេះ រាជរដ្ឋាភិបាលក៏នៅមិនទាន់បានឆ្លើយតបទៅនឹងសំណើររបស់សង្គមស៊ីវិល ដែលសុំឱ្យទទួលយកញត្តិ របស់ប្រជាពលរដ្ឋជាង១លាននាក់នោះនៅឡើយ។ សូមបញ្ជាក់ថាកិច្ចប្រឹងប្រែងរបស់សង្គមស៊ីវិល ក្នុងយុទ្ធនាការប្រមូលហត្ថលេខា ចំនួន១លាននេះ ក៏បានទទួលការគាំទ្រយ៉ាងខ្លាំងក្លាពីសំណាក់សហគមន៍អ្នកផ្តល់ជំនួយផងដែរ។

សម្ព័ន្ធអង្គការសង្គមស៊ីវិលប្រឆាំងអំពើពុករលួយចាប់អារម្មណ៍ថា លទ្ធផលនៃការស្ទង់មតិមួយ ដែលធ្វើឡើងដោយវិទ្យាស្ថានសាធារណរដ្ឋអន្តរជាតិរបស់សហរដ្ឋអាមេរិក ដែលហៅកាត់តាមភាសាអង់គ្លេសថា IRI ក្នុងចំណោមប្រជាពលរដ្ឋ ២០០០នាក់ ដែលត្រូវបានចេញផ្សាយនៅពេលថ្មីៗនេះ ត្រូវបានរាជរដ្ឋាភិបាលយកចិត្តទុកដាក់និងចាប់អារម្មណ៍យ៉ាងខ្លាំង។ ដូចគ្នានេះដែរ សម្ព័ន្ធអង្គការសង្គមស៊ីវិលប្រឆាំងអំពើពុករលួយយល់ឃើញថាហត្ថលេខានិងស្នាមមេដៃប្រជាពលរដ្ឋកម្ពុជាជាង ១លាននាក់ពិតជាចំនួនច្រើនណាស់ បើគិតទៅតាមចំនួនប្រជាពលរដ្ឋសរុប ហើយក៏មិនមែនមានន័យថាមានប្រជាពលរដ្ឋចំនួនតែជាង ១លាននាក់

នេះដែរដែលប្រឆាំងនឹងអំពើពុករលួយនិងចង់ឱ្យមានច្បាប់ប្រឆាំងអំពើពុករលួយ ។ ដរាបណាការប្រមូលហត្ថលេខានៅតែបន្តទៅមុខទៀត ដរាបនោះប្រជាពលរដ្ឋខ្មែរទូទាំងប្រទេសនឹងនៅតែបន្តចូលរួមផ្តិតមេដៃគាំទ្រ ។

ដូច្នេះសម្ព័ន្ធអង្គការសង្គមស៊ីវិលប្រឆាំងអំពើពុករលួយ មានជំនឿមុតមាំថារដ្ឋសភាក៏ដូចជារាជរដ្ឋាភិបាលនឹងពិចារណាដោះស្រាយទៅតាមការចង់បានរបស់ប្រជាពលរដ្ឋ ពោលគឺ អនុម័តច្បាប់ប្រឆាំងអំពើពុករលួយមួយដែលស្របតាមបទដ្ឋានអន្តរជាតិក្នុងពេលដ៏ឆាប់ខាងមុខនេះ ។

នៅពេលជាមួយគ្នានេះ សម្ព័ន្ធអង្គការសង្គមស៊ីវិលកម្ពុជាប្រឆាំងអំពើពុករលួយ ក៏បានផ្ញើលិខិតជូនផងដែរ ដល់គ្រប់គណបក្សនយោបាយទាំង១១ ដែលបានចុះបញ្ជីជាផ្លូវការប្រកួតប្រជែងក្នុងការបោះឆ្នោតនាពេលខាងមុខសូមឱ្យធ្វើការសន្យាជាឱឡារិកចំពោះមុខប្រជាពលរដ្ឋជាម្ចាស់ឆ្នោតថា ប្រសិនបើគណបក្សណាមួយឈ្នះឆ្នោត តើគណបក្សនោះនឹងធ្វើឱ្យច្បាប់ប្រឆាំងអំពើពុករលួយមួយដែលស្របតាមបទដ្ឋានអន្តរជាតិ នឹងជម្រុញឱ្យមានការអនុម័តយ៉ាងយូរបំផុតត្រឹមដំណាច់ឆមាសទី១នៃអាណត្តិថ្មីរបស់រាជរដ្ឋាភិបាល ។ សម្ព័ន្ធអង្គការសង្គមស៊ីវិលកម្ពុជាប្រឆាំងអំពើពុករលួយនឹងផ្សព្វផ្សាយជាសាធារណៈនៅមុនពេលបោះឆ្នោតនូវលទ្ធផលនៃការស្វែងរកកិច្ចសន្យាពីគណបក្សនយោបាយទាំង១១នេះ បើទោះបីជាមានការឆ្លើយតបក្តី មិនឆ្លើយតបក្តី ។

ភ្នំពេញ ថ្ងៃទី៩ ខែមិថុនា ឆ្នាំ ២០០៨

**តំណាងសម្ព័ន្ធអង្គការសង្គមស៊ីវិលកម្ពុជាប្រឆាំងអំពើពុករលួយ**